# គំនិតស្តីពីមុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងផ្លូវចិត្ត

## ការព្យាបាលរបួសស្នាមដោយសាររបបខ្មែរក្រហម

អង្គការចិត្តសង្គមអន្តរវប្បធម៌កម្ពុជា (TPO) ចាត់ទុកថា អ.វ.ត.ក ជាអ្នកទទួលខុសត្រូវដ៏សំខាន់លើសុខភាពផ្លូវចិត្តរបស់អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធបំផុតជាមួយ អ.វ.ត.ក និងបានគាំទ្រដល់គោលបំណងរបស់ អ.វ.ត.ក។ ដូច្នេះ មុខងារដែលនៅសេសសល់ពាក់ព័ន្ធនឹងផ្លូវចិត្ត ត្រូវបានចាត់ទុកជាអាទិភាពសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។ ពួកគេនៅតែត្រូវការការព្យាបាលរបួសស្នាម។ ទោះជាយ៉ាងណាក្តី សមត្ថភាពព្យាបាលរបួសស្នាមត្រូវបានប្រើប្រាស់សម្រាប់ជនរងគ្រោះទាំងអស់ ដែលត្រូវការសេវាផ្លូវចិត្ត ហើយក្រុមគ្រួសារ សាច់ញាតិផ្សេងទៀត និងអ្នកផ្សេងទៀតក្នុងសង្គមកម្ពុជា ពិតជានឹងទទួលបានអត្ថប្រយោជន៍ដោយប្រយោល ចំណែកអ្នកដែលអាចស្ថិតក្នុងដំណាក់កាលមួយចំនួននៃដំណើរការនេះក៏នឹងទទួលបានការគាំទ្រដោយផ្ទាល់លើបញ្ហាផ្លូវចិត្តរបស់ពួកគេ ឬការប្រឈមមុខជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះផ្ទាល់នៃរបបខ្មែរក្រហមផងដែរ។

**តម្រូវការផ្លូវចិត្តចុងក្រោយក្នុងអំឡុងពេលឈានទៅរកការបិទបញ្ចប់ អ.វ.ត.ក ៖**

១. ប្រសិនបើ អ.វ.ត.ក ត្រូវបិទដំណើរការ **នឹងមានការផ្តល់សំណាងផ្លូវចិត្តតាមរយៈសិក្ខាសាលាជាមួយដើមបណ្តឹងរដ្ឋប្បវេណី មុននឹងបិទដំណើរការ អ.វ.ត.ក** (ខ្លឹមសារនៃសិក្ខាសាលា មានដូចជា គន្លឹះស្តីពីការថែទាំខ្លួនឯង និងគន្លឹះផ្សេងទៀត)

២. **ក្នុងព្រឹត្តិការណ៍បិទដំណើរការនេះ ត្រូវអមដំណើរដោយតំណាងដើមបណ្តឹងរដ្ឋប្បវេណី។** តំណាងទាំងនោះជាក្រុមអ្នកចិត្តវិទ្យាដែលទទួលបានទំនុកចិត្ត។

៣. **ការគាំទ្រនៅនឹងកន្លែង/ការពិភាក្សាពន្យល់ផ្នែកផ្លូវចិត្តដោយបញ្ចប់សកម្មភាពនៅ អ.វ.ត.ក ៖** ដើមបណ្តឹងរដ្ឋប្បវេណីដែលមានវត្តមានក្នុងព្រឹត្តិការណ៍នេះ ឬជនរងគ្រោះផ្សេងទៀត អាចមានការរំជួលចិត្តខ្លាំង នៅពេលចូលរួមក្នុងព្រឹត្តិការណ៍បិទស្ថាប័ននេះ។ ជំនាញផ្លូវចិត្តឯកទេស និងការគាំទ្រផ្ទាល់ ពិតជាចាំបាច់ណាស់សម្រាប់ការកាត់បន្ថយព្យសនកម្មទូទៅ។

**តម្រូវការផ្លូវចិត្តដែលនៅសេសសល់ ៖**

៤. **សកម្មភាពផ្សព្វផ្សាយនៅ អ.វ.ត.ក ឬក្នុងសហគមន៍ ៖** សេវាផ្លូវចិត្តត្រូវជួយសម្រាលការមាក់ងាយ ។ ភាពអាចរកបាន និងប្រក្រតីភាពនៃសេវាផ្លូវចិត្ត ត្រូវស្តែងឡើងនៅ អ.វ.ត.ក និងក្នុងសហគមន៍ ។ ការបញ្ជូនអ្នកជំងឺដែលមានតម្រូវការផ្លូវចិត្ត គឺជារឿងសំខាន់។

៥. **ផ្តល់សេវាប្រឹក្សាតាមខ្សែទូរស័ព្ទបន្ទាន់ ៖** ខ្សែទូរស័ព្ទបន្ទាន់អាចដំណើរការបានទូទាំងប្រទេស និងផ្តល់ភាពងាយស្រួលដល់មនុស្សគ្រប់រូបដែលត្រូវការការគាំទ្រផ្នែកផ្លូវចិត្ត។ យ៉ាងហោចណាស់ សេវាជាច្រើនអាចចាប់ផ្តើមឡើងតាមទូរស័ព្ទ។

៦. **ផលិតសម្ភារព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC) ដើម្បីផ្សព្វផ្សាយពីសេវាសុខភាពផ្លូវចិត្តជា ច្រើន។** អង្គការ TPO ចង់បង្កើតសម្ភារព័ត៌មាន អប់រំ និងទំនាក់ទំនង ដែលមានទម្រង់ធម្មតាសម្រាប់បញ្ហាមួយចំនួន (ឧ. យុទ្ធសាស្ត្រដោះស្រាយការប៉ះទង្គិចផ្លូវចិត្ត ការថែទាំខ្លួនឯង ឬការជួយខ្លួនឯង និងការព្យាបាលរបួសស្នាម) ហើយតាមរយៈការប្រើប្រាស់សម្ភារទាំងនេះ អង្គការ TPO អាចផ្តល់ព័ត៌មាន អប់រំ និងផ្សព្វផ្សាយក្តីកង្វល់ជាក់លាក់ដល់អ្នកមានចំណាប់អារម្មណ៍នៅទូទាំងប្រទេស។

៧. **ផ្តល់ការព្យាបាលជំងឺវិកលចរិត និងការបញ្ជូន ៖** ដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកដែលទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយសារការប៉ះទង្គិចផ្លូវចិត្ត។ ក្នុងករណីមានរោគសញ្ញាធ្ងន់ធ្ងរបំផុត ពេលខ្លះចាំបាច់ត្រូវមានការផ្តួចផ្តើមព្យាបាលជំងឺវិកលចរិតសម្រាប់អ្នកជំងឺ ជាពិសេសនៅពេលចាប់ផ្តើមការព្យាបាលដំបូង។

៨. **ផ្តល់ការបណ្តុះបណ្តាលដល់អង្គការមិនមែនរដ្ឋាភិបាលជាដៃគូ** (និងក្រុមប្រឹក្សាសហគមន៍ អ្នកដឹកនាំសាសនា ឬអ្នកដឹកនាំយុវជន) **ស្តីពីការសង្គ្រោះបឋមផ្នែកផ្លូវចិត្ត (PFA) ការគាំទ្រផ្លូវចិត្ត និងការគ្រប់គ្រងភាពតានតឹង។** ជនរងគ្រោះនៃរបបខ្មែរក្រហម នឹងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើន ប្រសិនបើអ្នកដែលកំពុងធ្វើការតាមមូលដ្ឋាន មានចំណេះដឹងស្តីពីទស្សនាទានជាមូលដ្ឋាននៃការគាំទ្រផ្លូវចិត្ត និងភាពតានតឹង ព្រោះនេះជាគន្លឹះនៃការកាត់បន្ថយព្យសនកម្ម និងសាបព្រួសគំនិតខ្លះៗស្តីពីរបៀបប្រឈមមុខជាមួយបញ្ហាផ្លូវចិត្ត។

៩. **អន្តរាគមន៍វិបត្តិ ៖** ផ្អែកតាមបទពិសោធន៍កន្លងមក ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមានអារម្មណ៍អស់សង្ឃឹមចំពោះការបិទបញ្ចប់ អ.វ.ត.ក។ ពួកគាត់អាចមានអារម្មណ៍ឯកា និងយល់ថា ពួកគាត់នឹងលែងទទួលបានការគាំទ្រទៀតហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានប៉ុនប៉ងធ្វើអត្តឃាត និងត្រូវបានជួយគាំទ្រដោយទីប្រឹក្សាអង្គការ TPO បានទាន់ពេលវេលា។ ដូច្នេះ ក្រុមអន្តរាគមន៍វិបត្តិនឹង

ត្រូវបានបង្កើតឡើង  ដើម្បីឆ្លើយតបនឹងព្រឹត្តិការណ៍ដែលនឹកស្មានមិនដល់នេះ។  អន្តរាគមន៍នេះអាចធ្វើឡើងតាមខ្សែទូរស័ព្ទបន្ទាន់ ឬការផ្ដល់ប្រឹក្សាដោយផ្ទាល់។